**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ០៣ អនក្រ.បក**

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ០៥.នស.៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៦២ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ

- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្ដីពីការគ្រប់គ្រងសន្តិសុខឯកជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពនៅតាមទីតាំងរស់នៅប្រមូលផ្ដុំ ដើម្បីធានាដល់សន្តិសុខ សុវត្ថិភាពសង្គម និងសណ្ដាប់ធ្នាប់សាធារណៈ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះប្រធានអង្គភាព ឬម្ចាស់ទីតាំងរស់នៅប្រមូលផ្ដុំ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្ដុំ និងអ្នកស្នាក់នៅតាមទីតាំងរស់នៅប្រមូលផ្ដុំ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែកន្លែងស្នាក់នៅប្រមូលផ្ដុំរបស់កងយោធពលខេមរភូមិន្ទនិងកងកម្លាំងនគរបាលជាតិ។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ការត្រួតពិនិត្យរដ្ឋបាល** សំដៅដល់ការធ្វើបច្ចុប្បន្នភាពបញ្ជីស្នាក់នៅ ផ្ទៀងផ្ទាត់មនុស្សនិងបញ្ជី ឬការចុះត្រួតពិនិត្យជាក់ស្ដែងតាមទីតាំងរស់នៅប្រមូលផ្ដុំ
- **ការគ្រប់គ្រងសន្តិសុខសុវត្ថិភាព** សំដៅដល់ការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើដែលបង្កឱ្យមានការប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈ និងការត្រួតពិនិត្យប្រព័ន្ធការពារសន្តិសុខជាប្រចាំ
- **ទីតាំងរស់នៅប្រមូលផ្ដុំ** សំដៅដល់ទីសំណាក់ប្រមូលផ្ដុំ និង/ឬលំនៅឋានប្រមូលផ្ដុំនៃគ្រឹះស្ថានឬសហគ្រាសសាធារណៈឬឯកជន រួមមានបុរី ខុនដូ អាផាតមិន វីសេត បឹងកាឡូ អគារសហកម្មសិទ្ធិ រោងចក្រ សហគ្រាស កសិដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស តំបន់ដីសម្បទានសេដ្ឋកិច្ច ផ្ទះសំណាក់ សណ្ឋាគារ អន្តេវាសិកដ្ឋាន វត្តអារាម វិហារសាសនា និងមណ្ឌលថែទាំកុមារកំព្រា
- **ប្រធានអង្គភាព** សំដៅដល់បុគ្គលដែលត្រូវបានចាត់តាំងឱ្យដឹកនាំ ទទួលខុសត្រូវចំពោះទីតាំងរស់នៅប្រមូលផ្ដុំនៃស្ថាប័នឬអង្គភាពសាធារណៈរបស់រដ្ឋ
- **ម្ចាស់ទីតាំងរស់នៅប្រមូលផ្ដុំ** សំដៅដល់កម្មសិទ្ធិករនៃទីតាំងរស់នៅប្រមូលផ្ដុំ ដែលជានីតិបុគ្គលឬរូបវន្តបុគ្គល
- **អ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្ដុំ** សំដៅដល់ក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការគ្រប់គ្រងទទួលខុសត្រូវ ឬបុគ្គលដែលបានទទួលសិទ្ធិឬចាត់តាំងដោយអនុលោមតាមច្បាប់ ដើម្បីឱ្យទទួលខុសត្រូវចំពោះទីតាំងរស់នៅប្រមូលផ្ដុំនៃគ្រឹះស្ថានឯកជន។ អ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្ដុំ អាចជាម្ចាស់ទីតាំងរស់នៅប្រមូលផ្ដុំ

- **ប្រព័ន្ធការពារសន្តិសុខសុវត្ថិភាព** សំដៅដល់ការបំពាក់ឧបករណ៍សម្ភារៈបច្ចេកទេស ជាអាទិ៍ប្រព័ន្ធកាមេរ៉ាសុវត្ថិភាព ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ប្រព័ន្ធភ្លើងបំភ្លឺផ្លូវ ជណ្តើរយន្ត និងច្រកចេញចូលអគារ និង/ឬបរិវេណនៃទីតាំងរស់នៅប្រមូលផ្តុំ
- **ប្រព័ន្ធការពារសន្តិសុខ** សំដៅដល់ការរៀបចំយន្តការ ឬវិធានការ ឬប្រព័ន្ធផ្តល់សញ្ញាអាសន្នដល់រូបវន្តបុគ្គលក្នុងកិច្ចការពារទប់ស្កាត់គ្រោះថ្នាក់ឬហានិភ័យដែលកើតឡើង។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចដឹកនាំអនុវត្តអនុក្រឹត្យនេះ។

ក្រសួងមហាផ្ទៃធ្វើប្រតិភូកម្មការងារគ្រប់គ្រងការស្នាក់នៅនិងការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ ជូនរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវមានគណនេយ្យភាពចំពោះក្រសួងមហាផ្ទៃ ក្នុងការអនុវត្តការងារដែលបានទទួលប្រតិភូកម្មពាក់ព័ន្ធនឹងការគ្រប់គ្រងការស្នាក់នៅនិងការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ។

## ជំពូកទី៣
## វិធានការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ

**មាត្រា៥ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានតួនាទីជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដឹកនាំ ត្រួតពិនិត្យ និងជំរុញការអនុវត្តការងារគ្រប់គ្រងការស្នាក់នៅតាមទីតាំងរស់នៅប្រមូលផ្តុំ។

**មាត្រា៦ .-**

ស្នងការនគរបាលរាជធានី ខេត្ត និងអធិការនគរបាលក្រុង ស្រុក ខណ្ឌ មានតួនាទីជាសេនាធិការជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ លើការរៀបចំធ្វើផែនការនិងដឹកនាំគ្រប់គ្រងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ក្នុងការអនុវត្តផែនការការងារគ្រប់គ្រងការស្នាក់នៅតាមទីតាំងរស់នៅប្រមូលផ្តុំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៧ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដឹកនាំការងារគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចតម្រូវឱ្យប្រធានអង្គភាព ឬអ្នកគ្រប់គ្រងឬអ្នកតំណាងនៃទីតាំងរស់នៅប្រមូលផ្តុំ ផ្តល់បញ្ជីឈ្មោះអ្នកស្នាក់នៅ និងឯកសារសម្គាល់ការស្នាក់នៅ និង/ឬឯកសារផ្សេងៗពាក់ព័ន្ធនឹងការស្នាក់នៅតាមទីតាំងរស់នៅប្រមូលផ្តុំ ជូនសមត្ថកិច្ចពាក់ព័ន្ធលើការងារគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមការកំណត់។

**មាត្រា៨ .-**

ស្នងការនគរបាលរាជធានី ខេត្ត និងអធិការនគរបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើជាសេនាធិការជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រៀបចំធ្វើផែនការនិងដឹកនាំគ្រប់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ អនុវត្តផែនការការងារត្រួតពិនិត្យរដ្ឋបាល ដើម្បីរក្សាសន្តិសុខសុវត្ថិភាពនៅតាមទីតាំងរស់នៅប្រមូលផ្តុំ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៩ .-**

ស្នងការនគរបាលរាជធានី ខេត្ត និងអធិការនគរបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំដល់ប្រធានអង្គភាព ឬម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ក្នុងការផ្តល់របាយការណ៍អំពីចំនួនអ្នកស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្តុំរបស់ខ្លួន ឱ្យបានទៀងទាត់តាមពេលកំណត់។

ស្នងការនគរបាលរាជធានី ខេត្ត និងអធិការនគរបាលក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចរៀបចំផែនការចុះត្រួតពិនិត្យគុណភាពប្រព័ន្ធការពារសន្តិសុខសុវត្ថិភាពនៃទីតាំងរស់នៅប្រមូលផ្តុំ ដើម្បីធានាឱ្យបាននូវសន្តិសុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋដែលស្នាក់នៅតាមទីតាំងនោះ។

**មាត្រា១០ .-**

ស្នងការនគរបាលរាជធានី ខេត្ត និងអធិការនគរបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិកំណត់ឱ្យគ្រឹះស្ថានឯកជន និង/ឬភ្នាក់ងារផ្តល់សេវាសន្តិសុខឯកជន ដែលទទួលខុសត្រូវក្នុងការផ្តល់សេវាសន្តិសុខនៅក្នុងទីតាំងរស់នៅប្រមូលផ្តុំ ត្រូវផ្តល់កិច្ចសហការរាយការណ៍ពីមុខសញ្ញាសង្ស័យដែលអាចនឹងបង្កគ្រោះថ្នាក់និង/ឬមុខសញ្ញាដែលមានការចង្អុលបង្ហាញពីអាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវសហការជាមួយសមត្ថកិច្ចជំនាញពាក់ព័ន្ធ ក្នុងការចុះត្រួតពិនិត្យគុណភាពប្រព័ន្ធការពារសន្តិសុខសុវត្ថិភាពនៅតាមទីតាំងរស់នៅប្រមូលផ្តុំ ឱ្យបានទៀងទាត់តាមពេលកំណត់។

**មាត្រា១១ .-**

ការរៀបចំប្រព័ន្ធការពារសន្តិសុខសុវត្ថិភាពនៃទីតាំងរស់នៅប្រមូលផ្តុំ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៤

## ភារកិច្ចក្នុងការចូលរួមគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ

**មាត្រា១២ .-**

ប្រធានអង្គភាព ឬម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ មានភារកិច្ចដូចខាងក្រោម៖

១- កត់ត្រាអ្នកស្នាក់នៅទាំងអស់ ចូលក្នុងបញ្ជីទៅតាមទម្រង់ជាក្រដាសនិង/ឬទម្រង់ជាអេឡិចត្រូនិក ដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។ បញ្ជីឈ្មោះអ្នកស្នាក់នៅ អាចកត់ត្រាដោយដៃនិង/ឬដោយប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងផ្តល់បញ្ជីឈ្មោះអ្នកស្នាក់នៅទៅអាជ្ញាធរមានសមត្ថកិច្ចតាមការកំណត់។

២- រាយការណ៍អំពីការប្រែប្រួលអ្នកស្នាក់នៅក្នុងទីតាំងរបស់ខ្លួនគ្រប់គ្រង ដល់មន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់។

៣- សហការនិងបង្កលក្ខណៈងាយស្រួលក្នុងការអនុវត្តភារកិច្ចចុះត្រួតពិនិត្យរដ្ឋបាលរបស់អាជ្ញាធរមានសមត្ថកិច្ចតាមការកំណត់។

**មាត្រា១៣ .-**

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ត្រូវរាយការណ៍អំពីវត្តមានស្នាក់នៅបណ្តោះអាសន្នរបស់ជនបរទេសក្នុងទីតាំងស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន ក្នុងរយៈពេល២៤(ម្ភៃបួន)ម៉ោងយ៉ាងយូរ ដល់មន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬមន្ត្រីនគរបាលមានសមត្ថកិច្ច។

**មាត្រា១៤ .-**

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ មុននឹងអនុញ្ញាតឱ្យជនបរទេសស្នាក់នៅក្នុងទីតាំងស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន ត្រូវឱ្យជនបរទេសផ្តល់ឯកសារបញ្ជាក់អំពីសិទ្ធិស្នាក់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា។

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ មិនត្រូវអនុញ្ញាតឱ្យជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្តុំដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួនឡើយ។

**មាត្រា១៥ .-**

ជនបរទេសអន្តោប្រវេសន្តឬអ្នកតំណាងដែលមានប្រកាសទទួលស្គាល់ដោយក្រសួងមហាផ្ទៃនិងទទួលបានបណ្ណស្នាក់នៅអចិន្ត្រៃយ៍មានសុពលភាព មានកាតព្វកិច្ចរាយការណ៍ដើម្បីចុះបញ្ជីស្នាក់នៅក្នុងរយៈពេលយ៉ាងយូរ៤៨(សែសិបប្រាំបី)ម៉ោង ស្របតាមច្បាប់ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ជនបរទេសក្រៅពីប្រភេទជនបរទេសអន្តោប្រវេសន្តខាងលើ ដែលស្នាក់នៅតាមទីតាំងរស់នៅប្រមូលផ្តុំត្រូវចុះបញ្ជីស្នាក់នៅតាមច្បាប់ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៦ .-**

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ត្រូវផ្តល់ប្លង់ប្រព័ន្ធសន្តិសុខសុវត្ថិភាពនៃអគារស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្តុំដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ដល់អាជ្ញាធរមានសមត្ថកិច្ចតាមការស្នើសុំ។

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ត្រូវថែរក្សាឱ្យបានហ្មត់ចត់នូវគុណភាពប្រព័ន្ធសន្តិសុខសុវត្ថិភាពនៃអគារស្នាក់នៅនិង/ឬបរិវេណនៃទីតាំងរស់នៅប្រមូលផ្តុំ ឱ្យបានត្រឹមត្រូវតាមនិយាមបច្ចេកទេស។

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ត្រូវអនុវត្តតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការកែលម្អប្រព័ន្ធការពារសន្តិសុខ។

**មាត្រា១៧ .-**

ភ្នាក់ងារសន្តិសុខឯកជន ត្រូវមានកាតព្វកិច្ចត្រួតពិនិត្យ សហការ និងរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ឬប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ច អំពីសកម្មភាពល្មើសឬជនសង្ស័យដែលមាននៅតាមទីតាំងរស់នៅប្រមូលផ្តុំ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ឬក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន និង/ឬភ្នាក់ងារសន្តិសុខឯកជន ត្រូវចូលរួមសហការអនុវត្តដោយការទទួលខុសត្រូវ។

## ជំពូកទី៥
## ការរក្សាទុកនិងការប្រើប្រាស់ទិន្នន័យក្នុងកាមេរ៉ាសុវត្ថិភាព

**មាត្រា១៨ .-**

ទិន្នន័យទាំងស្រុងដែលមានក្នុងកាមេរ៉ាសុវត្ថិភាពក្នុងទីតាំងរស់នៅប្រមូលផ្តុំ ត្រូវរក្សាទុកក្នុងរយៈពេលយ៉ាងតិច៩០(កៅសិប)ថ្ងៃ ដើម្បីជូនមន្ត្រីមានសមត្ថកិច្ចតាមការស្នើសុំ។

ទិន្នន័យក្នុងបញ្ជីកំណត់ត្រាចេញចូលនៃការស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្តុំ ត្រូវរក្សាទុកក្នុងរយៈពេលយ៉ាងតិច១(មួយ)ឆ្នាំ ដើម្បីជូនមន្ត្រីមានសមត្ថកិច្ចតាមការស្នើសុំ។

## ជំពូកទី៦
## ទណ្ឌកម្ម

**មាត្រា១៩ .-**

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ដែលធ្វេសប្រហែសខកខានមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា១៦នៃអនុក្រឹត្យនេះ ត្រូវផាកពិន័យជាប្រាក់ចំនួន៤០០ ០០០(បួនសែន)រៀល ដោយមិនទាន់គិតដល់ព្យសនកម្មដែលកើតឡើងពីការធ្វេសប្រហែសនេះឡើយ។

**មាត្រា២០ .-**

ម្ចាស់ទីតាំងរស់នៅប្រមូលផ្តុំឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ដែលមានចេតនាលាក់បាំង និងអនុញ្ញាតឱ្យជនបរទេសដែលចូលមកព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ស្នាក់នៅក្នុងទីតាំងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ត្រូវផាកពិន័យជាប្រាក់ចំនួន៤ ០០០ ០០០(បួនលាន)រៀល សម្រាប់ជនបរទេសម្នាក់ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដែលបានកំណត់ក្នុងច្បាប់ជាធរមានឡើយ។

**មាត្រា២១ .-**

អាជ្ញាធរមានសមត្ថកិច្ចដែលមិនបានបំពេញតួនាទីរបស់ខ្លួនដោយភាពស្មោះត្រង់ មានចេតនាលាក់បាំងជនបរទេសដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ឱ្យស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្តុំណាមួយក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវទទួលរងទណ្ឌកម្មវិន័យបណ្តេញចេញពីក្របខ័ណ្ឌការងារ ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌដែលបានកំណត់ក្នុងច្បាប់ជាធរមានឡើយ។

**មាត្រា២២ .-**

បែបបទនិងនីតិវិធីនៃការផាកពិន័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ២រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ